# ផលិតកម្មដំណាំបន្លែនៅក្នុងផ្ទះសំណាញ់

# VEGETABLE PRODUCTION IN NET HOUSE

កុម្ភៈ ២០២៣ | **February 2023**

**អ្នកនិពន្ធ៖** ជា គឹមអ៊ន ,សុខ ស៊ីមាន, ជា លាងស្រ៊ុន, ហុក លីដា

មជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភ (ស៊ីសេន)

## ប្រភពថវិកា៖

ជំនួយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈ
មជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភ (ស៊ីសេន)

## សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

កញ្ញា ជា គឹមអ៊ន
លេខទូរសព្ទ៖ (៨៥៥) ៧៧ ២១៧ ០៧៥
សារអេឡិចត្រូនិច៖ ckeomorn@rua.edu.kh

## កម្មវិធីផ្សព្វផ្សាយកសិកម្មស៊ីសេន

## CE SAIN Agricultural Extension Program

កម្មវិធីនេះមានគោលបំណងជួយសម្របសម្រួលដល់កសិករស្ថាប័នអប់រំនិងស្រាវជ្រាវវិស័យឯកជន និងតួអង្គទីផ្សារកសិកម្មផ្សេងទៀតក្នុងការទទួលបានចំណេះដឹង ព័ត៌មានបច្ចេកវិទ្យានិងនវានុវត្តន៍កសិកម្មដើម្បីធានាបាននូវការចែកចាយការអនុវត្តការគ្រប់គ្រងនិងនវានុវត្តន៍បច្ចេកទេសកសិកម្មល្អៗ។



ការដាំដុះដំណាំប៉េងប៉ោះក្នុងផ្ទះសំណាញ់

## ១. ហេតុអ្វីធ្វើការដាំដុះដំណាំនៅក្នុងផ្ទះសំណាញ់?



សារៈសំខាន់នៃការដាំដុះដំណាំក្នុង**ផ្ទះសំណាញ់**រួមមាន៖ ផ្តល់ទិន្នផលខ្ពស់ គុណភាពល្អ និងសុវត្ថិភាពសម្រាប់ការបរិភោគ ព្រមទាំងកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន។ លើសពីនេះ ផ្ទះសំណាញ់ផ្តល់លទ្ធភាពដល់កសិករក្នុងការដាំដុះដំណាំបន្លែនៅក្នុងលក្ខខណ្ឌមិនសមប្រកប (ឧ. រដូវវស្សា) កាត់បន្ថយការប្រើប្រាស់កម្លាំងពលកម្ម និងថ្នាំកម្ចាត់សត្វល្អិត ប្រសិនបើធៀបទៅនឹងការដាំដុះនៅទីវាល។

## ២. មុខងាររបស់ផ្ទះសំណាញ់





- ☑ អាចធ្វើការដាំដុះបានទាំងដំណាំបន្លែ (បន្លែស្លឹក និងបន្លែផ្លែ) គ្រឿងទេស រុក្ខជាតិឱសថ និងរុក្ខជាតិផ្សេងៗទៀតដែលសមស្របក្នុងការដាំដុះក្នុងផ្ទះសំណាញ់
- ☑ ការពារដំណាំពីការបំផ្លាញពីសត្វល្អិតចង្រៃ និងជម្ងឺ



- ☑ បង្កើនភាពងាយស្រួលក្នុងការគ្រប់គ្រងការប្រើប្រាស់ទឹក
- ☑ អាចប្រើប្រាស់សម្រាប់ជាថ្នាលបណ្តុះកូនដំណាំ



ថ្នាលបណ្តុះកូនក្នុងផ្ទះសំណាញ់



កូនដំណាំនៅក្នុងផ្ទះសំណាញ់

## ៣. ការជ្រើសរើសប្រភេទ និងប្រព័ន្ធដាំដុះដំណាំ

ប្រភេទដំណាំដែលសមស្រប មានដូចជា បន្លែស្លឹក ដំណាំគ្រឿងទេស ដំណាំមើម និងបន្លែយកផ្លែស្វ័យដំណើរលម្អង(ឧ. ប៉េងប៉ោះ ត្រប់ ម្ទេស...)។



ការដាំដុះ**ដំណាំឆ្លាស់** និង**ដំណាំបង្វិល** ជាប្រព័ន្ធដាំដុះដែលសមស្រប សម្រាប់ធ្វើការដាំដុះនៅក្នុងផ្ទះសំណាញ់ ដោយបង្កើនការប្រើប្រាស់ដីអោយមានប្រសិទ្ធភាព បង្កើនលទ្ធភាពដាំដុះ បង្កើនជីវជាតិដី កាត់បន្ថយវត្តមានស្មៅចង្រៃ ជំងឺ និងសត្វល្អិត។



ដំណាំឆ្លាស់ (ឧ. ប៉េងបោះ/ខ្ទឹមស្លឹក)




## ៤. ប្រព័ន្ធស្រោចស្រព

- ➤ ប្រព័ន្ធដំណក់ទឹក (Drip Irrigation System) សមស្របសម្រាប់បន្លែយកផ្លែ និងដំណាំដែលដាំជាជួរ
- ➤ ប្រព័ន្ធសាចទឹក (Sprinkler Irrogation System) សមស្របសម្រាប់បន្លែយកស្លឹក និងដំណាំគ្រឿងទេស

**សម្គាល់៖** ក្រៅពីប្រព័ន្ធស្រោចស្រពខាងលើ ប្រព័ន្ធបាញ់ចំហាយត្រជាក់ (Mist Spray System) ក៏អាចប្រើប្រាស់ដើម្បីបញ្ចុះសីតុណ្ហភាព និងបង្កើនសំណើមនៅក្នុងផ្ទះសំណាញ់បានដែរ។



ប្រព័ន្ធដំណក់ទឹក (Drip Irrigation System)



ប្រព័ន្ធសាចទឹក (Sprinkler Irrogation System)



ប្រព័ន្ធបាញ់ចំហាយត្រជាក់ (Mist Spray System)